ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពត៌មាន
MINISTRY OF INFORMATION
លេខ ៤៤១ ព.ម

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ ៧ ឆ្នាំ ២០០៧

## បទបញ្ជា

កន្លងមក លោក លោកស្រី ចាងហ្វាងកាសែត ព្រឹត្តប័ត្រ និងទស្សនាវដ្តីមួយចំនួនបានខិតខំយកចិត្តទុកដាក់អនុវត្តតាមការណែនាំ ឬសេចក្តីក្រើនរំលឹករបស់ក្រសួងព័ត៌មាន ព្រមទាំងអនុវត្តតាមក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន បានត្រឹមត្រូវដែលជាការរួមចំណែកលើកស្ទួយវិស័យព័ត៌មាននៅព្រះរាជាណាចក្រកម្ពុជា ។

ទន្ទឹមនឹងនេះ ក្រសួងព័ត៌មានបានពិនិត្យឃើញថាមានលោក លោកស្រី ចាងហ្វាងកាសែត ព្រឹត្តប័ត្រ និងទស្សនាវដ្តី មួយចំនួនទៀត មិនបានអនុវត្តតាមការណែនាំ ឬសេចក្តីក្រើនរំលឹករបស់ក្រសួងព័ត៌មាន ក៏ដូចជាក្រមសីលធម៌ និងច្បាប់ស្តីពីរបបសារ-ព័ត៌មានឡើយ ។ ដើម្បីរក្សាតម្លៃ និង លើកតំកើងវិជ្ជាជីវៈសារព័ត៌មានឱ្យសមស្របតាមច្បាប់ស្តីពី របបសារព័ត៌មាន ក្រសួងព័ត៌មានចេញបទបញ្ជាណែនាំ ដល់បណ្តាអង្គភាពកាសែត ព្រឹត្តិប័ត្រ ទស្សនាវដ្តី រោងពុម្ពទាំងអស់ រាល់ការបោះពុម្ពផ្សាយត្រូវប្រតិបត្តិតាមខ្លឹមសារសំខាន់ និងចាំបាច់ដូចតទៅ :

- ត្រូវដាក់ឈ្មោះចាងហ្វាង ឬ រចនាសម្ព័ន្ធរបស់អង្គភាព អាស័យដ្ឋានទីស្នាក់ការ ឈ្មោះរោងពុម្ព និងលេខលិខិតអនុញ្ញាត របស់ក្រសួងព័ត៌មាន ។
- ត្រូវអនុវត្តតាមគោលការណ៍ណែនាំនានារបស់ក្រសួងព័ត៌មាន ។
- មិនត្រូវសរសេរ អធិប្បាយ ឬបរិយាយអំពីអ្វីដែលនាំឱ្យប៉ះពាល់ដល់ព្រះមហាក្សត្រ សន្តិសុខសណ្តាប់ធ្នាប់សង្គម ។
- មិនត្រូវប្រើពាក្យអសុរោះ ពាក្យចំអក ពាក្យចោទប្រកាន់ ប្រមាថ ឬ គូររូបថ្លុកដោយយកសត្វធាតុ មកប្រៀបប្រដូចចំពោះសាសនា ស្ថាប័នទាំងឡាយដូចជា ព្រឹទ្ធសភា រដ្ឋសភា និងថ្នាក់ដឹកនាំរាជរដ្ឋាភិបាល ។
- មិនត្រូវចុះផ្សាយរូប ឬអត្ថបទអាសអាភាស ប្រាសចាកពីសីលធម៌ វប្បធម៌ប្រពៃណីជាតិ ។
- រោងពុម្ព និងតូបកាសែត មិនត្រូវបោះពុម្ព និងដាក់លក់ កាសែត ព្រឹត្តប័ត្រ ទស្សនាវដ្តី ដែលបោះពុម្ពផ្សាយផ្ទុយនឹងបទបញ្ជានេះ ។

ការប្រព្រឹត្តផ្ទុយនឹងបទបញ្ជាខាងលើនេះ ក្រសួងព័ត៌មាននឹងមានវិធានការដកហូតប្រកាសអនុញ្ញាតឱ្យបោះពុម្ពផ្សាយ និងបើកអាជីវកម្មវិញ ។

ក្រសួងព័ត៌មានសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ចាងហ្វាងការផ្សាយ និងម្ចាស់រោងពុម្ពទាំងអស់ នឹងអនុវត្តន៍តាមបទបញ្ជានេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

រដ្ឋមន្ត្រី

ខៀវ កាញារីទ្ធ

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យអគ្គមេធាវីរាជរដ្ឋាភិបាល
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- គ្រប់សមាគមអ្នកសារព័ត៌មានកម្ពុជា "ដើម្បីជូនជ្រាប ព័ត៌មាន"
- មន្ទីរព័ត៌មានខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ